# ការសំភាសន៍របស់អ្នកមីង សាន សុដា

កៈ អ្នកដែលសំភាសន៍ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ សាន សុដា

## ការសង្ខេបរបស់អ្នកមីង សាន សុដា

អ្នកមីងសាន សុដាគាត់កើតនៅមុនរបបលន់ នល់ ២ឆ្នាំហើយគាត់កើតមកជាកូនអ្នកស្រែចំការហើយឪពុកគាត់ក៏បានរកស៊ីជួញដូរខ្លះដែរ គឺគាត់ធ្លាប់ជួញបង្កង ។នៅក្នុងនេះគាត់បានប្រាប់អំពីអនុស្សាវរីយ៍ជាមួយបងប្អូនដូនតាឪពុកម្តាយ ហើយគាត់ស្រលាញ់ឪពុកគាត់ណាស់ ។ ជីវិតរបស់អ្នកមីងក៏មិនសូវស្រួលប៉ុន្មាន គាត់បានរកស៊ីលក់លៀសហាលដើម្បីចិញ្ចឹមកូនហើយគាត់មានកូនស្រីដែលមានជំងឺប្រចាំកាយ ហើយប្តីគាត់ក៏មានស្រីធ្វើអោយគាត់ពិបាកចិញ្ចឹមកូនតែម្នាក់ឯង ជីវិតគាត់គាត់តស៊ូច្រើន។

កៈជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនាងខ្ញុំឈ្មោះ ញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះហើយថ្ងៃដែលពួកយើងសំភាសន៍គឺនៅក្នុងខែ មករា ឆ្នាំ២០១៨ ការសំភាសន៍នេះគឺមានទីតាំងគឺនៅក្នុងភូមិលេខ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។ហើយអឺចឹងអើរនាងខ្ញុំសូមចាប់ផ្តើមធ្វើការសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងតែម្តង។អឺចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញរបស់អ្នកមីងហាំ!!

ខៈឈ្មោះខ្ញុំឈ្មោះកំនើតឈ្មោះសាន សុដា។

កៈសាន សុដា??

ខៈចាំ!!

កៈឈ្មោះពិរោះណាស់អ្នកមីង!!

ខ៖កើតឆ្នាំ១៩៦៨។

ក៖ចាំ!!អ៊ីចឹងអ្នកមីងមានចាំថាអ្នកមីងកើតថ្ងៃណាខែណាអត់??

ខ៖ថ្ងៃខែអត់ចាំ!!

ក៖ចាំតែឆ្នាំទេអ្នកមីង??

ខ៖ចាំ!!

ក៖តែឆ្នាំទេណោះ??

ខ៖ចាំតែឆ្នាំ។

ក៖អ៊ីចឹងអ្នកមីងមានឈ្មោះហៅខាងក្រៅទេ??

ខ៖អត់!!!

ក៖ឈ្មោះតែសាន សុដា ហ្នឹងមួយ??

ខ៖ចាំ!!

ក៖នៅពីក្មេងមកមានដែលអ្នកណាគេដាក់ងារអីអោយទេបងប្អូន??

ខ៖អត់ទេ!!

ក៖ហៅតែសុដាអ៊ីចឹងម៉ង??

ខ៖ចាំ!!

ក៖ហ្នឹងហើយពិពោះណាស់មីង !!អ្នកណាគេជាអ្នកដាក់អោយវិញមីង??

ខ៖ម៉ែញុំម។

ក៖មិនមែនឪទេហេ៎??

ខ៖អត់ទេ។

ក៖ចាំ!!អ៊ីចឹងអ្នកមីងសំរាប់សព្វថ្ងៃនេះអ្នកមីងមានអាយុប៉ុន្មានហើយ?

ខ៖ហ៎ ៥០ហើយមិនដឹង ៥០គត់មិនដឹង៥១មិនដឹង!!

ក៖ហ្ហូ!!

ខ៖ព្រោះអីបូកទៅ៦៨(១៩៦៨)មក២០១៨!!

ក៖ចាំ!!ចឹងបើចង់គិតគិតតាមឆ្នាំហ្នឹងទៅដឹងហើយ!!

ខ៖ចាំ!!

ក៖ដឹងថាអាយុប៉ុន្មានហើយសព្វថ្ងៃហ្នឹងហ្ហូ!!អ្នកមីងឆ្នាំខ្មែរកើតឆ្នាំសត្វអីគេវិញអ៊ីចឹង?

ខ៖សត្វស្វា។

ក៖វកហ៎??

ខ៖ចាំ!!

ក៖មីងភាគច្រើនអ្នកកើតឆ្នាំវកមានអារម្មណ៍ថា
គេនិយាយថារៀងចរិកឆេវឆាវមីងហ៎??អ៊ីចឹងមីងអ៊ីចឹងទេ??

ខ៖អ៊ីចឹង ត្រូវកាំបិត កាំបិត ត្រូវពូថៅពូថៅ ។

ក៖ត្រូវកាំបិត កាំបិត ត្រូវពូថៅពូថៅអ៊ិចឹងម៉ង??

ខ៖ចាំ!!

ក៖ចឹបានអ៊ិចឹង
??មានអារម្មណ៍ថាម៉េចដែរនៅពេលដែលកើតឆ្នាំហ្នឹងដល់ពេលមានអារម្មណ៍អ៊ីចឹង??

ខ៖ទេ!!អោយតែខឹងមួយឆាវទៅហើយទប់មិនបានទេ!!ហើយអត់ចេះគុមទេ!!មកវិញ។

ក៖ល្អធម្មតាវិញទៅ??

ខ៖ចាំ!!មួយឆាវទៅហើយ!!អត់ទេបានទេ»!!

កះអីៗទៅហេ៎??

ខះចា៎!!

កះតែអ្នកមីងពេលខ្លះត្រូវទប់ដែរ វវវហ្នឹងពិបាក !!ចា៎អ៊ីចឹងអ្នកមីងសំរាប់ទីកន្លែងកំណើតរបស់អ្នកមីងអ្នកមីងកើតនៅក្នុងភូមិឃុំអីគេដែរ?

ខះញុំមកើតនៅស្រុកព្រះស្ដេច ឃុំនគររាជ ស្រុកព្រះស្ដេច ខេត្តព្រៃវែង!!

កះអ្នកស្រុកព្រៃវែង។

ខះភូមិហារ!!

កះភូមិមហារ?

ខះភូមិហារ!!

កះភូមិហារ??

ខះចា៎!!

កះហ្ហ៎!!ចា៎!!អ្នកមីងអើរនៅកន្លែងហ្នឹងនិយាយទៅនៅព្រៃវែងហ្នឹងប៉ុន្មានឆ្នាំទៅបានមករស់នៅទីក្រុងភ្នំពេញវិញ?

ខះខ្ញុំចេញពីស្រុកកំណើតញ៉ុមយូរហើយប៉ុន្តែញ៉ុមទៅនៅកំពង់ចាម ស្រុកមេមត់ឆ្នាំ៩០(១៩៩០)ខ្ញុំចូលមកក្រុងភ្នំពេញ!!

កះហ្ហ៎!!អ៊ីចឹងអ្នកមីងមកនៅភ្នំពេញយូរហើយអ៊ីចឹងហេ៎??

ខះចា៎!!មកឆ្នាំ៩០(១៩៩០)។

កះអ៊ីចឹងពីឆ្នាំ៩០(១៩៩០)មកទល់ឥឡូវហ្នឹង??

ខះចា៎!!

កះហ្ហ៎!!ហើយដីផ្ទះនៅនេះជួលគេឬក៏ម៉េច?

ខះជួលគេ។

កះជួលគេ មួយខែគេយកប៉ុន្មាន?

ខះផ្ទះហ្នឹង១ខែ២៥រៀល។

កះហ្ហ៎!!អឺចឹងមកនៅហ្នឹងតាំងពី៩០(១៩៩០)មិនព្រមចាប់ផ្ទះអីមួយឬក៏ទិញផ្ទះអីមួយទៅពេលមុនថោកណាស់មីងហា៎!!!

ខះដីពីមុនថោកតែរកស៊ីលក់តែលៀសប៉ុន្តែគេដេញពីសង្កាត់ទន្លេបាសាក់ហ្នឹងទៅនៅសែនសុខ។

កះហ្ហ៎!!គេដេញរហូតហ្នឹងមែន ញ៉ុមឮ??

ខះចា៎!!

កះហ៊ឺ!!!

ខះទៅនៅសែន សុខរាល់ថ្ងៃផ្ទះ ផ្ទះពិតប្រាកដនៅសែន សុខ។

កះចា៎!!

ខះតាមសហាគមន៍មិនមែនដីឡូតិ៍ទេ!!

កះហ្ហ៎ស្គាល់ហើយពេលមុនញ៉ុមធ្លាប់ធ្វើការនៅហ្នឹងដែរ!!

ខះចា៎!!

កះស្គាល់ហើយនៅកន្លែងសែន សុខហ្នឹងហ្ហ៎!!តែផ្ទះមានសព្វថ្ងៃនៅសែនសុខហ្នឹង??

ខះចា៎!!

កះតែគ្រាន់តែមកនៅនេះគ្រាន់តែនៅបណ្តោះអាសន្ន!!

ខះចា៎!!

កះមកធ្វើការរកស៊ី!!

ខ៖ចាំ!!

ក៖ចាំ!! អ៊ីចឹងអ្នកមីងសំរាប់ចូលដល់សមាជិកក្រុមគ្រួសាររបស់អ្នកមីងវិញម្តង តើអ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ខ្ញុំបងប្អូនញ៉ុមបង្កើតមានគ្នា៤នាក់ប្រុសមួយស្រីបី ញ៉ុមបងគេ។

ក៖ចាំហ្នឹងហើយ ហើយអ៊ិចឹងអ្នកមីងជាកូនបងគេ?

ខ៖ចាំ!!

ក៖អ៊ីចឹងសំរាប់ប្អូនរបស់អ្នកមីងគាត់ឈ្មោះអីគេខ្លះអ្នកមីងអាចរៀបរាប់ពីបងរហូតដល់ពៅ??

ខ៖ប្អូនញ៉ុមបន្ទាប់ពីញ៉ុមស្រីឈ្មោះ សាន ច្រឹប ទីពីរ សាន ហាន ទីបី សាន វណ្ណ ពៅស្រី។

ក៖ហ្នឹងហើយ ឥឡូវពួកគាត់នៅឯណាដែរមីង?

ខ៖នៅសែន សុខទាំងអស់។

ក៖អ៊ីចឹងពេលមុនកើតនៅស្រុកភូមិព្រៃវែងហ្នឹងជាមួយគ្នា!!

ខ៖ចាំ!!

ក៖មករស់នៅនេះជាមួយគ្នាអ៊ិចឹងទៅ?

ខ៖ចាំ!!

ក៖ហ្ហ៎!!អ៊ីចឹងអ្នកមីងសំរាប់នេះហាំ!អ្នកមីងមានចងចាំសាច់អីគេខ្លះតាំងពីក្មេងជាមួយបងប្អូនរបស់អ្នកមីងតើម៉េចដែរ អ្នកមីងអាចនិយាយពីជីវិតអ្នកមីងជាមួយបងប្អូនធ្លាប់ធ្វើអីគេខ្លះជាមួយគ្នាលេងឬក៏ញ៉ាំបាយឬក៏ធ្វើការអ៊ីចឹងហាំ!!អ្នកមីងអាចរៀបរាប់??

ខ៖ជាមួយបងប្អូនញ៉ុមហោ??

ក៖ចាំ!!

ខ៖កាលឆ្នាំ៨៦(១៩៨៦)៨៧(១៩៨៧)ញ៉ុមទៅនៅខេត្តបាត់ដំបងទៅនៅហ្នឹង ហើយត្រលប់ទៅច្រូតលូវិញធ្វើលូនៅស្រុកអើរពាមជ ជិតព្រំដែនយួន ខ្សាច់កាលីហ៎!!

ក៖ហ៊ឺ!!

ខ៖ដល់តែពេលហ្នឹងច្រូតលូអីហើយក៏មានយាយតាញ៉ុមទៅជួយច្រូត លូហ្នឹង៣ ៤ ៥ហិចតាហ៎!!ដល់យប់មួយប៉ាញ៉ុមអត់នៅទេ ចោរប្លន់ណាស់ មេឃរលឹមច្រិចៗ ពួកឈន់ឈាងទៅលេងនៅវត្តអើរអំពៅព្រៃ យប់ហ្នឹងចោរប្លន់ក្រុមគ្រួសារញ៉ុមពិបាក!!

ក៖ចំ!!

ខ៖ដល់ហើយគេយកអស់រលីង សល់លុយតែ៣០០០លុយខ្មែរទេកាលហ្នឹងហ្ន៎!!៣០០០លុយខ្មែរទិញបានក្របីមួយនឹម!!

ក៖ហ៊ឺ!!

ខ៖ក៏នាំម៉ែកូនមកនៅស្រុកកំណើតវិញ ដល់មកនៅស្រុកកំណើ តបាន៤ ៥ខែមានបងប្អូនជីដូនមួយនាំទៅនៅស្រុកមេមត់ទៅនៅឆ្នាំ៨៧(១៩៨៧)ហ្នឹងឆ្នាំ៩០(១៩៩០) បានត្រលប់មកវិញ
ទៅហ្នឹងដាំសណ្ដែកសៀងដីគេអោយហ៎!!ត្រួសត្រាយមានមីនមានអីដែរហ្នឹងហ៎!!ដល់ហើយយើងនាំគ្នាចេះតែអត់អីនាំបងប្អូនត្រួសត្រាយដាំសណ្ដែកសៀងដឹកចូលយួនហ្នឹង ដល់ឆ្នាំ៩០(១៩៩០)ញ៉ុមត្រលប់មកវិញក៏ម៉ែញ៉ុមប៉ាញ៉ុមក៏មកតាមទៅ មកនៅភ្នំពេញរហូតទៅ។

ក៖ចា៎!!អ៊ីចឹងអ្នកមីងចងចាំសាច់រឿងដែលសប្បាយជាងគេជាមួយបងប្អូន ធ្លាប់លេងអីគេខ្លះជាមួយគ្នាដែរមីង?

ខ៖ញ៉ុមជាមួយបងប្អូនញ៉ុមមិនដែលលេងអីទេ!!អត់ដែលសោះ!!

ក៖ចុះពេលនៅផ្ទះនៅអីម៉េចទៅ??

ខៈនៅផ្ទះបើនៅផ្ទះកាលសម័យមុនហ្នឹង
សម័យកាលមិនទាន់ទៅរកស៊ីស្រុកគេប៉ាញ៉ុមទៅហ្នឹងមានតែចេញពីរៀនមកនាំគ្នាជិះក្របីទៅបឹងហ្នឹង ឡើងពីបឹងហ្នឹងរើសអុសចូលផ្ទះតែប៉ុណ្ណឹងហ្នឹង!!

កៈចាំ!!

ខៈគ្មានធ្វើអីទេ គ្មានដែលលេងអីជាមួយបងប្អូនបង្កើតសប្បាយៗទេ
បើថាជាមួយអ្នកដទៃបងប្អូនជីដូនមួយអីមានតែលេងគប់វង់
មែន!!ជាមួយប្រុសៗជីដូនៗមួយហ្នឹងលេងតែគប់វង់ទេត្រលប់មកពីមើលក្របីមើលអីវិញហ្នឹង
ហើយម៉ែជេរម៉ែអីទៅរឿងដើរលេងជា មួយមនុស្សប្រុសនោះ និយាយមែន!!

កៈហ្នឹងហើយ ញ៉ុមអីចឹងដែរ!!

ខៈញ៉ុមមិនដែលមានលេងអីទេ លេងប៉ុណ្ណឹង។

កៈចាំ!!ហើយអ៊ីចឹងអ្នកមីងសំរាប់បងប្អូនរបស់អ្នកមមីង ប្អូនៗនៅ៣នាក់ទៀតមីងណេះ??

ខៈចាំ!!

កៈស្រលាញ់មួយណាជាងគេបងប្អូន?

ខៈស្មើគ្នា។

កៈស្មើគ្នាទាំងអស់ហេ៎??

ខៈចាំ!!ញ៉ុមមិនដែលស្រលាញ់ប្អូនណាចោលប្អូនណាទេ
បើថាមានអីបន្តិចបន្តួចទៅប្អូនរកទៅអោយទៅបើថាអត់ប្រាប់វាថាអត់អ៊ិចឹងទៅ!!រាល់ថ្ងៃហ្នឹង
ហើយប្អូនញ៉ុមអ៊ិចឹងដែរបើមានលុយមានកាក់អីទៅញ៉ុមខ្វះខាតអីអោយ ។

កៈចាំ!!

ខៈបើប្អូនញ៉ុមបន្ទាប់ពីខ្ញុំហ្នឹងមិនសូវអោយខ្ញុំទេបើប្តីវាអោយខ្ញុំបើខ្ញុំខ្វះខាតអីចឹង
កាលខែវស្សាផ្ញើរមកអោយកូនញ៉ុម១០០ អីអ៊ិចឹងទៅ!!ធ្វើមាសធ្វើអីអោយកូនញ៉ុមពាក់ទៅ
អាហ្នឹងប្អូនថ្លៃហា៎!!

ក៖ហ៊ឺ!!

ខ៖តែប្អូនញ៉ុមស្រីបន្ទាប់ពីខ្ញុំ!!

ក៖ចាំ!!

ខ៖រាល់ថ្ងៃហ្នឹងក៏ដោយ ហើយដល់នាំម៉ែកូនមករកស៊ីហ្នឹងហ៎!! កូននេះក៏ឈឺពិបាកពេក ដកមីមួយហ្នឹងលែងអោយរៀន កូនញ៉ុមរៀនថ្នាក់ទី៨ បើនៅរៀនដល់ឥឡូវបានធ្វើការនៅអង្គការ តែញ៉ុមពិបាកពេកជំពាក់គេច្រើនពេក បញ្ចូលឈាមរាល់ខែមីពៅនេះ ក៏ខ្ញុំដកកូនអោយមកជួយលក់លៀសទៅ!!ចុះបើមួយខែឈាម មួយខែដាក់ឈាមៗ ចងការគេផងអីផងអាហ្នឹងវាពិបាកវេទនាពេកទៅយកកូនមួយអោយមួយយកមកជួយលក់បានធូរបន្តិចទៅហើយកូ នហ្នឹងក៏លែងដាក់ឈាម២ឆ្នាំហើយមកដែរ វាអស់លុយ។

ក៖គាត់ឈឺអីគេបានដាក់ឈាមមីង?

ខ៖ វះហើយនៅតែអ៊ិចឹងទៀត ពោះធំហ្នឹង។

ក៖ហើយមាននាំទៅពេទ្យគន្ធបុប្ផាទេ?

ខ៖ញ៉ុមចេញ អង្គការលីកាដូអីជួយញ៉ុមទាំងអស់ហ្នឹង កូនញ៉ុមហ្នឹងហ្នំ!! ដល់ពេលទៅពេទ្យគន្ធបុប្ផាគេបញ្ជូនទៅពេទ្យកុមារមជ្ឈឹមហ្នឹងបានវះហ្នឹង អាយុ៦ឆ្នាំបានវះ!!

ក៖ហ៊ឺ!!

ខ៖ហើយអង្គការផ្សេងៗទៀតជួយអោយប្រាក់កាក់អោយអីយើងដេកពេទ្យបានវះហ្នឹងហ៎!! ដល់ពេលយើងបញ្ចូលឈាមគេលែងជួយហាំ!!

ក៖ហ៊ឺ!!

ខ៖ឈប់ទៅ ហើយអង្គការនានាហ្នឹងដូចថាមកជួយបានម្តងអ៊ីចឹងអោយអង្ករត្រីខអីហើយទៅបាត់ទៀតទៅ!!

កះហ៊ិ!!

ខះហើយគេថាអោយញ៉ុមយកចិត្តទុកដាក់ជាមួយអង្គការហើយញ៉ុមយកចិត្តទុកដាក់ជាមួយធ្វើម៉េច ក្មួយឯងគិតមើល!!គេថតអីហើយ
ហ៊ីហ៊ី!!ដល់យើងនិយាយទៅចេះតែថាយើងនិយាយគេមានប្តីមានអីគេមានស៊ីគេមានលុយគ្រប់គ្រាន់អស់ហើយនៅជួយតែអ្នកហ្នឹងអាយើងអ្នកក្រគេដែលជួយយើងស្អី
ដូចនៅសែនសុខកូនញ៉ុមខំទៅរៀនអង្គការទស្សនៈពិភពលោកមិនអោយអីបានម្តង
ឈ្មោះកូនញ៉ុមសុទ្ធតែបញ្ជូនទៅ សុទ្ធតែមានម៉េចម៉ិម៉ែអី ចុងក្រោយបានតែអ្នកធ្វើការ
កូនអានាក់ធ្វើការ ធ្វើក្រុមធ្វើប្រធានអីហ្នឹង
ទៅអ៊ីចឹងទៀតទៅហើយយើងគ្មានអារម្មណ៍ទេនិយាយរួមក្រៅតែពីកំលាំងខ្លួនឯងរកស៊ីចិញ្ចឹមខ្លួនឯងទៅទៅពឹងអីគេ!!គិតតែអ៊ិចឹងរាល់ថ្ងៃ
ហ៊ីឃើញគេហៅអោយទៅនេះទៅណោះអីខ្ញុំ មិនសូវចង់បានរបស់
របស់គេក្រៅពីខ្លួនឯងរកហាំ!!

កះចាំ!!

ខះនិយាយទៅ អោយឃើញក្មួយអើយ!!

កះចាំ!!

ខះហើយដល់ឆ្នាំហ្នឹងលក់លៀសហ្នឹងវេទនាទៀតហើយ!!

កះភ្លៀង!!

ខះភ្លៀងរាល់តែថ្ងៃក្នុងប៉ុន្មាន គ្រឿងក្នុងមួយថ្ងៃ៨០០០០!!

កះហ៊ី!!

ខះគិតមើលទៅ!!ហើយលៀសគេ៣តៅឃើញប៉ុន្មានហើយ គិតមើល!!អាថ្លៃ៨០០០០ !!

កះហ៊ីៗ!!

ខ៖ ៨០០០០ ៦០០០០ ៥០០០០ ធន់ថោក ហើយលក់បានមួយកំប៉ុង ៣០០០ ២៥០០បើអស់ទៅយើងក្នុងមួយថ្ងៃចំនេញបានកូន១០០០០ដូចថាញ៉ុមលក់អស់ទៅអីអឺចឹងបូកចូលគ្នាបាន៣០០០០ ៥០០០០អីដែរតើ!!

ក៖ចំនេញហេ?

ខ៖ចាំ!!មួយថ្ងៃហ្នឹង តែបើយើងលក់មិនបានអត់ជំពាក់គេហើយជំពាក់គេទៀត គិតទៅអាថៅកែហ្នឹងគេចេះតែកត់ទៅអាហើយយើងចេះតែជំពាក់គេ គេចេញសងអាថ្លៃលៀសអ្នកបោះដុំយកមកអោយហាំ!!អោយឃើញ។

ក៖តែពេលខ្លះអើរនៅពេលដែលមានភ្លៀងមានអីអ៊ិចឹងខាងលក់លៀសគេយល់ដែរតើហ៉ោំ!!

ខ៖អត់ទេឆ្នាំមុនៗថៅកែមុនៗបើយកទាល់តែមេឃភ្លៀងលែងយកលុយដែរ ឥលូវឆ្នាំនេះលៀសថ្លៃ វាល់របស់គេត្រូវតែសងគេពេញៗ អត់មានថាហ៊ីមេឃភ្លៀងចោលអត់មានទេ!! គេទារយើងគ្រប់គ្រប់ម៉ង បើយើងជំពាក់គេគេកត់ទុកក្នុងបញ្ជីគេ គេចេញលុយអោយថៅកែធំទៅ ថ្ងៃណាយើងរកបានយើងសងគេទៅ។

ក៖ហើយលៀសហ្នឹងគេចិញ្ចឹមឬក៏លៀសទន្លេមឹង?

ខ៖លៀសទន្លេ ហ៊ីអារឿងលៀសចិញ្ចឹម ចចាមអារាមទេក្មួយអើរ!!

ក៖គ្មានម៉ងហ៉ោំ?

ខ៖គ្មានម៉ង ទៅអាណាចិញ្ចឹមមកតាមខេត្តក្មួយឯងគិតមើលទៅ ព្រៃវែង ស្វាយរៀង កំពង់ធំ ហើយកោះធំ កំពង់ចាម ខាងរកាកោង ខាងអីអ៊ិចឹងទៅ!!

ក៖សំបូរម៉ងមឹងហ៉ោំ??

ខ៖សំបូរ!!ហើយខេត្តតាកែវលៀសអន់ជាងគេ ខ្មៅៗទូចៗបើមកពីស្អាងល្អហើយនឹងខាងរកាកោងហើយខាងណោះទន្លេបិទ កោះប៉ែនហ្នំ!!

ក៖ហ្វយ!!អាហ្នឹងឆ្ងាញ់ម៉ងមឹង!!

ខះអាហ្នឹងល្អ អាត្រប៉ែតប៉ុនៗមេជើងខៀវៗហ្នឹង។

កះហ្នឹងហើយ!!អូយ!!

ខះអាលៀសហ្នឹងមួយតៅ១៣០០០០។

កះតែឆ្ងាញ់ណាស់មីង!!

ខះតែឆ្នាំហ្នឹងយកមកម្តង ហើយគេអត់ហ៊ានយកហើយមេយអ៊ីចឹងទៀត
មានអាណាជឹកចូលៀឡូវគ្មានទេ!!

កះថ្លៃពេកណោះមីងណោះ?

ខះចាំ!!

កះអ៊ិចឹងអ្នកមីងមានចាំរឿងអីជាមួយប្អូនៗទៀតទេ?

ខះអ់តមានទាល់តែសោះ គ្មានទេ។

កះចាំ!!ឥឡូវពួកគាត់ទាំងអស់គ្នានៅសែនសុខទាំងអស់?

ខះចាំ!!

កះអ៊ីចឹងមានគ្រួសារអីគ្រប់គ្នាអស់ហើយហ៉េ??

ខះមាននៅប្អូនពៅម្នាក់ ។

កះអាយុប៉ុន្នានប្អូនពៅ?

ខះអូយអាយុច្រើនហើយតែអត់យកប្តីទេ!!ធ្វើការរោងចក្រ។

កះថីបានមិនយកប្តី?

ខះមិនយកទេ។

កះមិនស្រលាញ់តែម្តងហ៉េ?

ខ៖មិនដឹងទេ គេដណ្តឹងតែគេមិនយកទេតាំងពីនៅក្មេងមកដល់ឥឡូវ មិនយកទេ អត់។

ក៖ទៅអ៊ីចឹងទៅណោះ!!សុខចិត្តនៅម្នាក់ឯង?

ខ៖ចាំ!!

ក៖ចាំហ្នឹងហើយ !!អ៊ីចឹងអ្នកមីងចូលដល់ឪពុកម្តាយរបស់អ្នកមីងវិញម្តង
អ្នកមីងតើឪពុកអ្នកមីងឈ្មោះអីគេដែរ?

ខ៖ប៉ាញ៉ុមគាត់ឈ្មោះ សាន ហូល។

ក៖ហូល?

ខ៖ចាំ!!ហើយម៉ែញ៉ុមឈ្មោះទូចណៃ។

ក៖ទូច ណៃ?

ខ៖ចាំ!!

ក៖អ៊ិចឹងអ្នកមីងសំរាប់ឪពុកសិន មីងដូចដឹងថាគាត់កើតឆ្នាំណាទេឪពុក?

ខ៖ញ៉ុមអត់ដឹងផង តែដឹងថាគាត់អាយុច្រើនហើយប្រហែលគាត់ខ្ទង់៧០អស់ហើយ។

ក៖តែឥឡូវគាត់នៅរស់ទេអ្នកមីង?

ខ៖នៅរស់ទាំង២។

ក៖ចាំអ៊ីចឹងទាំងឪពុកនៅរស់ទាំងម្តាយនៅរស់?

ខ៖ចាំ!!

ក៖តែដឹងតែថាខ្ទង់៧០ឡើង!!

ខ៖ចាំ!!

ក៖ប្រហែល៧០ប៉ុន្មានមីង បើប្រាកដហាំ??

ខះបើម៉ែញ៉ុមបងប៉ាញ៉ុម៥ឆ្នាំដឹងគាត់៧០ជាងមិនដឹង៧០ប៉ុន្មានទេ!!មិនដឹងដែរដឹងតែ៧០ជាងអស់ហើយ។

កះហ្នឹងហើយ។

ខះប៉ាញ៉ុមគាត់កើតឆ្នាំចហើយម៉ែញ៉ុមឆ្នាំមមី ដឹងតែប៉ុណ្ណឹង!!

កះចាំ!

ខះតែដឹងតែ៧០ជាងមិនដឹង៧០ប៉ុន្មាន។

កះអ៊ីចឹងមីងចាំកន្លែងកំណើតរបស់ម៉ែឪទេ?ឥឡូវឪពុកសិនកន្លែងកំណើតគាត់នៅឯណាវិញ?

ខះប៉ាញ៉ុមគាត់នៅឃុំជាយកំពក ស្រុកព្រះស្តេចដែរ។

កះនៅព្រៃវែងហ្នឹងដែរ?

ខះចាំ!!

កះចុះម្តាយ?

ខះម្តាយញ៉ុមនៅឃុំនគររាជ ស្រុកព្រះស្តេច ភូមិហារហ្នឹងស្រុកកំណើតគាត់តែម្តង ។

កះហ្អូអ៊ីចឹងសុទ្ធតែអ្នកស្រុកព្រៃវែង!!

ខះអ្នកស្រុកព្រៃវែង។

កះអ៊ីចឹងអ្នកមីងអ៊ិចឹងសំរាប់ម្តាយរបស់អ្នកមីងមីងមានការចងចាំអីគេដែលស្រលាញ់គាត់ជាងគេដក់ជាប់ក្នុងចិត្តជាងគេហាំ??

ខះម៉ែញ៉ុមស្រលាញ់ ម៉ែប៉ាស្រលាញ់ស្មើរគ្នា គ្មានអីដក់ជាប់ក្នុងចិត្តអី។

កះដឹងតែស្រលាញ់ស្មើគ្នា!!

ខះចាំ!!

កះតែរបៀបថាម្តាយរបស់អ្នកមីងគាត់មានចរិកលក្ខណ:ម៉េចដែរអ៊ីចឹងហាំ??

ខះម៉ែញុំមរៀងកាចតែប៉ាញុំមចិត្តល្អជាងគេបន្តិច ម៉ែញុំមបើថាសុំអីមិនងាយអោយទេ បើប៉ាញុំមបើមានអោយ បើម៉ែញុំមជេរ អត់អោយទេ គាត់ថាមណាស់!!

កះចាំ!!

ខះបើរឿងលុយកាក់យើងចង់សុំដូចថាយើងនៅក្មេងៗអ៊ីចឹងយើងសុំ សម័យចាយ២កាក់ ៥កាក់ហ្នឹង គាត់មិនអោយ ទេ បើប៉ាញុំមមានអោយម្តង៥រៀលអោយម្តង១០រៀល កាលចាយលុយខ្មែរចេញមុនដំបូងហ្នំ!!

កះចាំ!!

ខះញុំមនៅទូចៗនោះ!

កះចាំ!!ចុះអ្នកមីងមានចាំសាច់រឿងអីថាតើឥឡូវគាត់រកស៊ីអីគេដែរដើម្បីចិញ្ចឹមអ្នកមីងមក?

ខះពីដើមមក?

កះចាំ!!

ខះពីដើមមកម៉ែញុំមមានរកស៊ីអី ពីដើមមកធ្វើតែស្រែហ្នឹង ហើយប៉ាញុំមរកស៊ីជួញដូរទៅខាងអូរជ្រៅអូរអីហាំ!!គាត់ជួញបង្កងជួញអីប៉ាញុំមគាត់រកស៊ី។

កះបង្កង?

ខះចាំ!!បែកអាពតហើយហ្នឹងគាត់ជួញបង្កងហើយគាត់បែកភ្លាមគាត់ទៅរកស៊ីឯណោះទៅឯជាយដែនហ្នំ!!!!គាត់ទៅយកខោអាវពីខាងថៃហ្នឹងយកមកលក់ មកបោះដំបោះរាយហ្នឹងហើយទៅលក់ដល់ស្រែហ្នឹងទៅហើយគាត់ដឹកពីស្រែទៅបាត់ដំបងវិញដឹកជ្រូកដឹកអីហ្នឹង!!

កះហ៊ុៗ!

ខះហើយបានគាត់ឈប់ដឹកជ្រូកបានគាត់ជួញបង្កង ឈប់ពីជួញបង្កងទៅគាត់ទិញម៉ាស៊ីនភ្លើងគេ ២ ៣គ្រឿងអ៊ីចឹងដើរតាមរោងបុណ្យរោងការហើយគាត់ជាងថតរូបហាំ!!

ក៖ហ្ង!!

ខ៖តាមពោ ងការរោងបុណ្យអ៊ីចឹងទៅ គាត់ចត្របផង
គាត់មានអាប្រដាប់លាងរបស់គាត់ស្រាប់ផងដល់ហើយគាត់ឈប់ទៅ។

ក៖ចា៎!!

ខ៖បានគាត់ទៅរកស៊ីនៅស្រុកគេទៅកំពង់ចាមធ្វើជាងផ្ទះរាល់ថ្ងៃហ្នឹងគាត់ធ្វើជាង ជាងធ្វើផ្ទះ។

ក៖ចា៎!!

ខ៖ទោះបីតែគាត់នៅចាស់ប៉ុណ្ណឹងក៏គាត់នៅតែធ្វើជាងផ្ទះរាល់ថ្ងៃហ្នឹង
ទោះគាត់៧០ជាងតែគាត់នៅតែធ្វើជាងរាល់តែថ្ងៃហ្នឹង។

ក៖ដោយសារគាត់ដូចសកម្មតាំងពីនៅក្មេងមក!

ខ៖ចា៎!!

ក៖អ៊ិចឹងសុខភាពល្អ ភាគច្រើនចាស់ៗសុខភាពល្អមិនមែនដូចយើងឥលូវទេមីងអើយ!!

ខ៖គាត់អត់សូវឈឺទេ បើប្អូនៗឈឺខ្លះស្លាប់អស់ហើយ មួយបងប្អូនគាត់ស្លាប់អស់ហើយ
នៅសល់តែ២នាក់អ៊ំញ៉ុមហើយគាត់ហ្នឹង។

ក៖ចា៎!!

ខ៖គ្មាននៅអ្នកណា។

ក៖ទៅបងៗនៅវិញ!!

ខ៖ចា៎!!

ក៖ប្អូនៗទៅអស់រលីងហើយ។

ខ៖ពូញ៉ុមស្លាប់អស់រលីងហើយ។

កៈចាំហ៊ី!!អ៊ីចឹងអ្នកមីងសំរាប់អើរដូចជាមិនអ៊ីចឹងក្រុមគ្រួសារអ្នកមីងមានខ្លាំងហើផយអ៊ីចឹងបើអំពុករបស់អ្នកមីងគាត់រកស៊ីម្លឹងៗ??

ខៈកាលពីមុនរកស៊ីធូរធារគ្រាន់បើដែរទឹមតែឥឡូវ!!

កៈចាំ!!

ខៈចោរប្លន់មួយសារ។

កៈហ្វូហ្នឹងហើយអ្នកមីងប្រាប់ថារឿងចោរប្លន់ហ្នឹង។

ខៈចោរប្លន់គាត់ទៅមួយសារទៅហើផយគាត់មានលុយគាត់ធូរអីអ៊ីចឹងទៅគេខ្ទីគាត់ហើយគេអត់សងហាំ!!!ដូចជាមាសអីខ្លើរគាត់ដូចជាបងប្អូនគាំតអី
៥ជី៦ជី៣ជីអីអត់មានអាណាសងដល់ឥឡូវហ្នឹងតាំងពិឆ្នាំហ្នឹងមក
ហើយឥឡូវគាត់ក៏វាមិនពិបាកហាហើយក៏មិនមានហើយក៏មិនក្រ
គាត់គ្រាន់តែថាគាត់មួយធូរធារសំរាប់ជីវិតរបស់គាត់។

កៈចាំ!!តែអ្នកមីងមានបានផ្តល់អីទៅអោយគាត់វិញទេទាំងពីរនាក់ម្តាយ?

ខៈអត់ដែលមានផ្តល់អីទៅអោយទេ
មានតែបើមានលុយអីអោយកូនទិញម្ហូបត្រីសាច់អីយកទៅអោយម្តងមួយយាមហ្នឹង។

កៈចាំ!!

ខៈតែប៉ុណ្ណឹង ហើយបើញ៉ុមអត់វិញមានតែទៅរកលុយគាត់។

កៈហ្នឹងហើយដោយសារជីវិត!!

ខៈខ្វះខាត។

កៈភាគច្រើនមនុស្សមិនចង់ពិបាកទេមីងមែនអត់??

ខៈចាំ!!

កៈតែធ្វើម៉េចបើវាទាល់ហើយ ដោ យសារឥឡូវរកលុយមិនស្រួលណាប៉ុន្មានទេមីង!!

ខះចាំ!!មិនងាយទេ!!កាលពីមុនមកលក់លៀ សលក់អីយើងមួយតៅ២
៣០០០អីយើងលក់ចំនេញបានមួយថ្ងៃ១០០០០ ២០០០០
កាលសម័យហ្នឹងហាំ!!កះហ៊ឺ!!ខះដល់សម័យឥឡូវអ្នកលក់ក៏ច្រើនលៀសក៏ថ្លៃ រកមិនបានទេ
គ្រប់កន្លែងហើយលក់ដូរតាមផ្សារក៏គេដេញទៀត ដេញហើយយកលុយយើងទៀត អា៥០០០
ផ្សេងអា២០០០ផ្សេង ក្មួយអើយវេទនាណាស់ឥឡូវហ្នឹង
ហ្ហ៎!!តាមទីផ្សារគេសុទ្ធតែដេញរទេះអីយើងនេះមិនអាចដាក់លក់បានទេឥលូវ។

កះចាំ!!

ខះពិបា កណាស់!!ហើយយើងរុញដើរតាមផ្ទះហ្នឹងក៏យ៉ាប់ទៀត
អានាក់ធ្លាប់ហូបៗហ្នឹងគេទៅលក់ផ្ទះហ្នឹងគេទៅទិញនៅតាមបុរីអីអិចឹងទៅ
យើងលក់មានសូវដាច់អី!!មិនដូចលើកមុនមនុស្សវាច្រើនណាស់!!

កះចាំ!!

ខះឥឡូវមិនងាយទេ បើសុទ្ធតែបរទេសនៅចង់ពេញអស់ហើយ!!

កះបរទេសយើងអ្នកណាគេទៅមីង??

ខះគេមិនសូវមិនសូវហូបដូចយើងខ្មែរ។

កះចាំ!!ភាគច្រើនហ្នឹងហើយខ្មែរចូលចិត្តណាស់រឿងលៀសហាលទាំងញុំមទាំងគេ។

កះលៀសខ្មែហើយនឹងវៀតណាម ចូលចិត្តហូប ដល់ពួកចិនពួកបារាំងអី
គេមានចេះហូបអីអាចឹងៗ យើងនិយាយតែគ្នាយើងទៅមានស្អី។

កះចាំហ្នឹងហើយ!!អ៊ីចឹងអ្នកមីងមានចាំសាច់រឿងអីគេខ្លះជាមួយម៉ែជាមួយប៉ាអីទៀតដែលគាត់
ធ្លាប់មីងនៅពីក្មេងគាត់ធ្លាប់យកអ្នកមីងទៅនៅណានៅអីទេ??

ខះហ៊ឺ មិនដែលទេ
មិនដែលនាំយកទៅលេងនៅឯណាបើគាត់ជួញបង្កងអិចឹងទៅបើខ្ញុំចង់មកជាមួយគាត់អិចឹង
ទៅជិះកាណូតមកតាមគាត់អ៊ីចឹងទៅដើរ ថ្លឹងបង្កងរងាចង់ងាប់ហ្នឹង!!

កះហ្ហ៎!

ខះមិនដែលដើរទៅលេងឯណា!!

កះបង្កងទន្លេ បង្កងទឹកប្រៃ??

ខះបង្កងយើងបង្កងទន្លេ តាមទន្លេតូច
ស្រុកពាមជហ្នឹងពេលខែទឹកលិចហ្នឹង!!គាត់មិនដើរទិញគេគាត់មិនដើរទិញដាក់អ៊ិចឹងទៅ
ដូចថាដាក់លបដាក់អីអ៊ីចឹងទៅ គាត់ម៉ោង៤ឡើងគាត់ដើរថ្លឹងបង្កងអ៊ិចឹងទៅ
ហើយដល់បានដល់ព្រឹកឡើងអ៊ីចឹងយើងយកមកលក់នៅភ្នំពេញអ៊ីចឹងទៅ។

កះបានចំនេញច្រើនដែរមីងហេ៎??បង្កងថ្លៃ!!

ខះមិនដឹងទេ មិនដឹងគាត់ ចំនេញប៉ុន្មានខាតប៉ុន្មានញ៉ុមមិនដឹងដែរកាលហ្នឹង!!

កះអ៊ិចឹងពេលមុនផ្ទះអ្នកមីងសំបូរបង្កងហូបណាស់ហេ៎??

ខះសំបូរបង្កងត្រីងៀតអីអត់ខ្វះទេ បង្កងសុទ្ធតែធ្វើបង្គាបញ្ឈរទាំងបាវហ្ន៎!!បង្គារក្រៀមៗ!!!
បង្កងហ្នឹងបកហាលអោយក្រៀមៗទៅដូចបង្គាយើងអ៊ិចឹង។

កះចា៎!!ហើយដែលយកទៅលក់អាក្រៀមៗហ្នឹងទេ??

ខះអត់ដែលលក់ទេ តែហូបហើយបងប្អូនជីតខាងសុំហើយម៉ែញ៉ុមទៅ
ម៉ែញ៉ុមអោយគេមួយដៃៗ!!

កះចា៎!!ញ៉ុមគិតថាបើសិនជាឥឡូហ្នឹងរកបង្កងហ្នឹងហា៎មីងមិនមែនក្រទេមីងហា៎!!បង្កងថ្លៃហា៎
១គីឡូរសុទ្ធតែ២០ដុល្លារឡើងហ្ន៎!!

ខះកាលហ្នឹងមិនដល់ប៉ុណ្ណឹងទេ មួយគីឡូរប៉ុន្មានពាន់ហ្នឹង!!ប៉ុន្មានរយហ្នឹង ទិញគេមិនដឹងដែរ!!

កះអើរ!!

ខះហើយអាបង្កងងាប់ៗទុកទៅស្ងោរបកហាល បើហូបណាយ!!

កះចា៎!!បើបានដូចមកឥឡូវវិញក្លាយជាអ្នកមានម៉ង ញ៉ុមធានា១០០%។

ខះអ្នកមានស្អី!!

កៈទៅរកស៊ីបង្កង មីងហាំ!! ឥឡូវមីងដល់ជីដូនជីតាខាងឪពុកសិន ចាំថាតាយាយឈ្មោះអីអត់ ខាងឪពុកមិនមែនខាងម្តាយទេ??

ខៈតាញ៉ុមឈ្មោះតាសាន។

កៈទាំងត្រកូលគាត់ហាំ??

ខៈអើរអ៊ុំ

កៈអ៊ុំ សាន ??

ខៈចាំ!!

កៈចាំ!!

ខៈហើយយាយខ្ញុំមិនដឹងឪគាត់ឈ្មោះអីញ៉ុមមិនដឹងទេដឹងតែគាត់ឈ្មោះយាយឡេង។

កៈយាយឡេង!!ឥឡូវគាត់នៅរស់ទាំង២អត់?

ខៈស្លាប់អស់ហើយ!!

កៈចាំ!!

ខៈស្លាប់យូរហើយស្លាប់!!យាយញ៉ុមស្លាប់៦ ៧ឆ្នាំហើយ។

កៈចាំ!!ហើយពេលគាត់ស្លាប់ហ្នឹងគាត់អាយុប៉ុន្មានមីង?

ខៈយាយញ៉ុមស្លាប់អាយុ៩៣។

កៈ៩៣??

ខៈចាំ!!

កៈហើយស្លាប់៧ឆ្នាំហោ?

ខៈចាំ!!

ក៖ចាំ!!ចុះតា?

ខ៖តាញ៉ុមស្លាប់តាំងពីខ្ញុំនៅតូចហ្នំ!!ញ៉ុមអត់ដឹងដែរ!!

ក៖អត់ដឹងស្លាប់ឆ្នាំណាទេអ៊ិចឹងហេ??

ខ៖ចាំ!!តាញ៉ុមស្លាប់យូរហើយ។

ក៖ចាំ!!អ៊ិចឹងគាត់ស្លាប់មុនជំនាន់សង្គ្រាមមីងណោះ??

ខ៖ស្លាប់ជំនាន់ដឹង៧០(១៩៧០)ប៉ុន្មានទេញ៉ូមអត់ដឹងដែរ!!

ក៖ចាំ!!

ខ៖៧២ ៧៣មិនដឹង៧០(១៩៧០)គត់មិនដឹង!!ជីតាញ៉ុម!!

ក៖ចាំ!!អ៊ីចឹងអ្នកមីងសំរាប់ពួកគាត់ស្រុកកំណើតនៅណាវិញសំរាប់តាយាយខាងឪពុក?

ខ៖ហ៊ីតាញ៉ុមគាត់នៅខាងភូមិអំពិលទឹកឃុំជ័យតាពកដដែលហ្នឹង!!

ក៖ចាំ!!ចុះយាយ?

ខ៖យាយញ៉ុមហ្នឹងគាត់នៅភូមិអំពិលទឹក គាត់
តាញ៉ុមគាត់នៅស្វាយទោលខាងលិចខាងកើតហ្នឹង។

ក៖ចាំ!!

ខ៖តែឃុំជាងតាពកស្រុកព្រះស្តេចដដែលហ្នឹង!!

ក៖ចាំ!!មីងកើតទាន់ពួកគាត់ទាំង២នាក់មែនទេ??

ខ៖ញ៉ុមតាញ៉ុមអត់ទាន់ទេញ៉ុមទាន់តែយាយទេ??

ក៖ហ្នំ!!តែតាមីងដូចរាងនៅក្មេងតែអត់ចាំគាត់ទេអ៊ីចឹងទេហេ៎??

ខ៖ខ្ញុំកើតមកមិនចាំអីបើញ៉ុមមិនដែលឃើញគាត់ផងហ្នឹង ញ៉ុមនៅទូចគាត់ស្លាប់យូរហើយ។

ក៖អ៊ីចឹងមានដែលមីងចាំអីគេខ្លះជាមួយតាហើយយាយ?

ខ៖ចាំ??

ក៖ដូចធ្លាប់លេងអីគេខ្លះជាមួយយាយ យាយដែលនិយាយអីលេងជាមួយអត់?

ខ៖យាយនិយាយលេងជាមួយយាយញ៉ុមអី?ក៖ចាំ!!ខ៖យាយញ៉ុមពេលគាត់មកលេងផ្ទះញ៉ុមម្ដងៗគាត់ប្រើញ៉ុមអោយទៅរើសខ្ចងនៅបឹងអោយយកមកអោយគាត់ហូប ២ ៣ថ្ងៃអ៊ីចឹងគាត់មកលេង មកលេងអ៊ីចឹងប្រើញ៉ុមហើយប្អូនញ៉ុមទៅរើសខ្យងមកអោយគាត់ស្ងោរហូបទៅហើយ ២ ៣ថ្ងៃគាត់ត្រលប់ទៅវិញទៅ។ក៖ចាំ!!ខ្មោចយាយញ៉ុមហាំ!!ក៖ចាំ!!ខ៖មានដែលមានចាំអីទេ!! ហើយបើញ៉ុមទៅលេងអីនៅផ្ទះគាត់ហ្នឹតង ញ៉ុមឡើងលេងតែនៅលើដើមខ្វិតហ្នឹង បេះស៊ីហើយលប់មកវិញទៅ!!នៅអីទៀត។

ក៖ហើយចុះតាវិញមានដែល ហាំមានដែលឪប្រាប់អត់ថាម៉េចៗអីអ៊ីចឹងហាំ??

ខ៖អត់ដែល!!

ក៖អត់ដែលនិយាយពីប្រវត្តិដូនតាប្រាប់សោះម៉ង??

ខ៖អត់ដែលសោះ អត់!!អត់មាននិយាយផង!!

ក៖ចាំ!!

ខ៖គ្រាន់តែម៉ែញ៉ុមនិយាយថាហ៊ីតាស្លាប់ទៅថាខ្ញុំកើតហើយតាស្លាប់ទៅ កើតបានប៉ុន្មានថ្ងៃគាត់ស្លាប់ញ៉ុមមិនដឹងដែរ!!ញ៉ុមមានឃើញគាត់អីណា!!

ក៖ចុះយាយមានចាំអីទៀតពីយាយទេ??តែគាត់ចរិកម៉េចដែរយាយ?ក្រៅពីរើសខ្ចងខ្ចៅអោយគាត់?

ខ៖យាយ ហ្នំយាយញ៉ុមអត់កាចអត់អីគាត់ស្លូត!!

ក៖ហ្នំ!!

ខះញ៉ុមមិនដែលនិយាយអីពាក្យសំដីអីធ្ងន់សំដីតូចអីដាក់ញ៉ុមទេ
អ៉តមានទេ!!យាយញ៉ុមស្លូតណាស់!!

កះមីងចាំគាត់កើតជំនាន់ណាទេទាំង២នាក់យាយតាហ្នឹង ជំនាន់យូរហើយហីអីមីង??

ខះហ៉េ!!គាត់មិនដឹងកើតជំនាន់ណាញ៉ុមមិនដឹងដែរហ្នឹងបើគាត់អាយុ៩០ជាងហើយញ៉ុមកើត៦
៨(១៩៦៨) គិតទៅជំនាន់ណាញ៉ុមមិនដឹងដែរ!!មីអូនហា៎!!

កះចាំ!!អត់អីទេអ្នកមីង!! អ៊ិចឹងអ្នកមីងចូលដល់ខាងម្ដាយវិញម្ដង
យាយតាកើតទាន់គាត់២នាក់អត់??

ខះយាយតាញ៉ុមស្លាប់ឆ្នាំប៉ុន្មានទេនេះបែកអាពតហើយស្លាប់ គាត់ស្លាប់អាយុ៦៤
!!កះហ្ហូ!!ខះមិនគាត់ស្លាប់ឆ្នាំប៉ុន្មានដែរ!!ដូច៨៥!!

កះ១៩៨៥?

ខះ៨៤(១៩៨៤)មិនដឹងទេ!!យាយញ៉ុមស្លាប់ឆ្នាំ៨៤(១៩៨៤)។

កះចាំហើយពេលហ្នឹងគាត់អាយុប៉ុន្មានវិញអ្នកមីង??

ខះ៦៤។

កះ៦៤ហ្នឹងបានស្លាប់ហ្នឹង??

ខះចាំ!!គាត់ឈឺប្រតិកម្មថ្នាំ!!

កះចំ!

ខះហើយតាញ៉ុមទឹមស្លាប់បានប៉ុន្មាន៤ឆ្នាំទេ គាត់អាយុ៩៧!!

កះយេ!!អាយុវែងណាស់មីង!!

ខះចាំ!!គាត់ទឹមស្លាប់ឥឡូវៗហ្នឹងដែរ!!

កះ៩៧ស្លាប់៤ឆ្នាំហើយ??

ខ៖ចាំ!!

ក៖អីចឹងស្លាប់ឆ្នាំ២០១៤??ដោយសារឥឡូវ២០១៨!!

ក៖ហ្នឹងហើយ!!

ខ៖៤ឆ្នាំហើយ!!

ក៖ចាំ!!អីចឹងអ្នកមីងពួកគាត់ទាំង២នាក់មានស្រុកកំនើតនៅឯណាវិញដែរ?

ខ៖យាយញ៉ុមនៅភូមិហារហ្នឹងពិតប្រាកដ!!

ក៖ចាំ!!

ខ៖ហើយតាញ៉ុមគាត់អើរខាងភូមិឬស្សីជុក បបោះរលួយហ្នុំ!!

ក៖បរបោះរលួយ!!ស្អីគេមីងអាហ្នឹង?

ខ៖នៅជាប់អើរ!!បន្ទាយគ្រែ។

ក៖អំបោះរលួយឬក័ម៉េចអាហ្នឹង??

ខ៖បោះរលួយ។

ក៖បង់រលួយ?

ខ៖បោះរលួយ៕

ក៖បោះរលួយ !!អាហ្នឹងពិបាកនិយាយហាំ!!

ខ៖តែនៅភូមិឬស្សីជុក គាត់នៅ!!

ក៖ចាំ!!

ខ៖នៅឃុំបន្ទាយគ្រែ!!

ក៖ចាំ!!

ខ៖នៅម្ដុំហ្នឹងហា៎!!នៅជាប់កាស៊ីណូយួន!!

ក៖ហ្អូ!!អ៊ីចឹងសុទ្ធនៅខេត្តព្រៃវែងទាំងអស់?

ខ៖ចា៎!!

ក៖នៅព្រៃវែងមកទាំងអស់ អ៊ីចឹងអ្នកមីងអនុស្សាវរីយ៍ជាមួយតាហើយនឹងយាយ ដោយសារមីងសុទ្ធកើតទាន់គាត់ហើយមែនទេ??

ខ៖ចា៎!!

ក៖ចាំអីគេខ្លះពីពួកគាត់ដែរ??

ខ៖ខ្ញុំពីជំនាន់ប៉ុល ពតមកញ៉ុមនៅទូចៗចាំតែគាត់ទៅលួចដកដំឡូងមកដុតអោយហូប ហ្នឹងជំនាន់ប៉ុល
ពតហា៎!!ហើយដល់ពេលបែក៧៩(១៩៧៩)៨០(១៩៨០)៨១(១៩៨១)៨២(១៩៨២)៨៣(១៩៨៣) ហ្នឹងខ្ញុំនៅរៀងតូចៗដែរ គាត់បេះម្អលភ្នំបេះអីយកមកស្លអោយហូប
ហើយនាំញ៉ុមទៅដកប្រាចអីមកបុកអោយជ្រូកស៊ី ចាំបានតែប៉ុណ្ណឹងហើយគាត់
ញ៉ុមដើរទៅលេងភូមិគេអ៊ីចឹងទៅណាស់ ជាមួយចាស់ៗហ្នឹង។

ក៖ចា៎!!

ខ៖ត្រលប់មកវិញ។

ក៖ហ្នឹងសំរាប់តាឬក៏យាយ?

ខ៖យាយ។

ក៖យាយហ៎េ??

ខ៖ចា៎!!

ក៖ចុះតាវិញម្ដង?

ខ៖តាគ្មានដើរទៅណាទេ!!មិនដែលដើរទៅណាជាមួយតាផង!!គ្រាន់តែពេលញ៉ុមចាំបានថាពេលគាត់ប្រាប់ញ៉ុមថាង៉ែងកុំអីងាប់ហើយនៅពីទូច
កើតដំបៅម៉ាហ៊ីម៉ាហ្វូរកាលជំនាន់ហ្នឹងកប៉ាល់ហោះគេទំលាក់គ្រាប់ហាំ!!គាត់ដាក់ញ៉ុមរែកតាមសង្រែកឆ្លងបឹង!!

ក៖ហ្ហ៎!!

ខ៖គាត់ប្រាប់ញ៉ុមថាអញ្ជឹងហាំ!!គេមិនយកង៉ែងទៅជាមួយទេ
កុំតែបានអញទេ!!ហ្នឹងខ្មោចតាញ៉ុមហាំ!! គាត់ដាក់អំរែករែកញ៉ូមទៅហាំ!!

ក៖ចាំ!!

ខ៖តែប៉ុណ្ណឹងញ៉ុមនៅចាំគាត់និយាយប្រាប់!!

ក៖ចាំ!!ចុះពេលជីវិតរបស់ពួកគាត់
មីងមានដឹងថាជីវិតរបស់ពួកគាត់ប្រកបរបរអីគេអត់ពេលជំនាន់យូរហើយ?

ខ៖យូរយូរហើយគាត់ចាស់បុរាណគាត់ធ្វើតែស្រែចំការទេ តាញ៉ុម ហើយយាយញ៉ុមហ្នឹងកូនគាត់ពីដើមគាត់ស្រួលហាំតា តាឪគាត់ហ្នឹងគាត់មេស្រុក។

ក៖ហោំ!!ឡូយ!!

ខ៖ចាំ!!តាមេស្រុកទូច
ហើយប្អូនគាត់ឈ្មោះតាប៉ាន់តាប៉ាន់ហ្នឹងគាត់ខាងកង់សីនៅភ្នំពេញហ្នឹងហិ!!ដល់ពេលជំនាន់ឆ្នាំ៧៥(១៩៧៥)មិនដឹងប៉ុន្មានមិនដឹងគេជំលៀសចេញពីភ្នំពេញគាត់បើកឡានចុះទន្លេស្លាប់ហាំ!!

ក៖អូយម៉េចអីចឹង?

ខ៖មិនដឹងទេ គាត់ស្តាយផ្ទះស្តាយអីគាត់
ផ្ទះគាត់នៅម្តុំពេទ្យចិនមួយនៅវិមានឯករាជ្យមួយហើយដីគាត់ទិញនៅគៀនស្វាយច្រើនណាស់
ហើយរាល់ថ្ងៃហ្នឹងអាឆ្នាំ៨៥(១៩៨៥)ហ្នឹងកូនតាប៉ាន់ឈ្មោះយាយញៀយាយញៀគាត់ខាងក្រសួ

ងមេព្រៃហាំតែឈ្មោះដើមគាត់ឈ្មោះយាយញៀ ដល់ពេល គាត់ធ្វើការឈ្មោះអ៊ុក សិលា នៅខេត្តបាត់ដំបងណោះ!!គាត់ក្រសួងមេព្រៃហើយពូប្អូនគាត់ពូឈីញហ្នឹងគាត់នៅប្រទេសបារាំង
ដល់ពេលឆ្នាំហ្នឹងគាត់យកញ៉ុមទៅនៅបាត់ដំបងនៅត្រើយខាងលិចហ្នឹងយកញ៉ុមទៅរៀនកាត់ដេរហើយអោយរៀន ហើយញ៉ុមរៀនកាលហ្នឹង សម័យហ្នឹងច្របូកច្របល់អាពតវាច្រើននោះ!!

កះហ៊ឺៗ!!

ខះហើយញ៉ុមអត់មានទៅរៀនទេ!!ដល់ពេលញ៉ុមទៅញ៉ុមនឹកផ្ទះញ៉ុមត្រលប់មកវិញទៅ ហើយឥឡូវហ្នឹងមិនដឹងថាគាត់នៅឯណាឯណីទេញ៉ុមមិនដែលបានដឹង ប្រវត្តិដែលញ៉ុមដឹងត្រួសៗតែប៉ុណ្ណឹង។

កះចាំ!!

ខះមានអីវែងឆ្ងាយទៀត។

កះចាំអ៊ីចឹងអ្នកមីងសំរាប់នៅក្នុងរបររកស៊ីរបស់អ្នកមីងការលក់លៀសសព្វថ្ងៃហ្នឹងម៉េចដែរ??របៀបថាបានគួរសមល្មមដើម្បីផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារដែរហោ?

ខះហ៊ឺក្មួយហ្អើយ លក់លៀសរាល់ថ្ងៃហ្នឹងលក់មួយថ្ងៃបានមួយថ្ងៃហ្នឹង!!

កះចាំ!!

ខះហូបបានមួយមកអ៊ីចឹងបើយើងបានចំនេញបានហូបចុកល្មាចហ្នឹងទៅស្អែកចាំគិតទៀតទៅគ្មានសល់គ្មានអីទេ!!អោយសល់អោយអីគ្មានទេ!!

កះហើយអ៊ីចឹងកូនចៅអីវ៉ានជួយតែ២នាក់ហ្នឹងទេហោ៎រកស៊ី??

ខះកូននេះគេមានប្តីមានប្រពន្ធគេរៀងខ្លួនហើយ !!

កះហ្ន៎!!

ខះហើយញ៉ុមនៅលីវ២នាក់នេះ!!

កះចាំ!!

ខ៖ប្រឹងលក់ទាំង៣នាក់ម៉ែកូនហ្នឹង។

ក៖ហ៊ឺៗ!!

ខ៖រាល់ថ្ងៃហ្នឹងហ្មំ!!

ក៖ចាំ!!ហើយលក់ទៅដល់ណាខ្លះទៅអ្នកមីង??មីនេះលក់នៅមុនសាលារៀនជ័យជំនះ មីនោះលក់នៅផ្សារអូឡាំពិក។

ក៖នេះលក់ដែរ?

ខ៖ចាំ!!

ក៖លក់លៀសដែរ?

ខ៖ចាំ!!

ក៖យេ!!ហើយអត់ឈឺអត់អីទេចុះ?

ខ៖ដឹក!!ឈឺតែវារុញរទេះអត់រួចទេ ញ៉ុមអូសជីះម៉ូតូអូសទៅអីចឹងដាក់ នៅអង្គុយចាំលក់ទៅណាស់!!ពេលកូនញ៉ុមមីនេះត្រលប់មកវិញលើករទេះអូស២នាក់បងប្អូន ហ្នឹងមក ហើយខ្ញុំដើររុ ញលក់ធម្មតា។

ក៖ហើយស្គាល់លុយទាំងអស់ហ៎?

ខ៖ស្គាល់អាប់បានទាំងអស់!!

ក៖អូយ!!!

ខ៖រាល់ថ្ងៃហ្នឹងហ្មំ!!

ក៖ហ៊ឺអានិតណាស់!!!

ខ៖បើទៅលក់ទៅលក់ទាំង៣នាក់ម៉ែកូនហ្នឹងថ្ងៃណានេះ!!ហើយបើមេឃថ្ងៃណានេះមួយខែល ក់មួយថ្ងៃខាន២ ៣ថ្ងៃ។

ក៖ចាំ!!

ខ៖ថាអស់ហើយមានស្អីទៀតឥឡូវ ។

ក៖ហ្នឹងហើយ អ្នកមីងពិបាកដៃរដល់ពេលអិចឹង!!តែប្រឹងរកទៅថ្ងៃក្រោយនឹងគ្រាន់បើ!!

ខ៖ដៃបាក់នេះធ្លាក់ពីលើរទេះទេនេះ!!បាក់ហិ!!

ក៖បាក់ដៃទៀត??

ខ៖ចាំ!!

ក៖កូន!!ដល់ពេលនេះនៅក្នុងភូមិអីគេនេះអីវ៉ាន់អីចឹងទៅ
!!មីងមកនៅក្នុងភូមិនេះប៉ុន្មានឆ្នាំហើយ?

ខ៖មកនៅ មកនៅម្លុកហ្នឹង៣ឆ្នាំហើយ។

ក៖ចាំ!!

ខ៖មកនៅ៣ឆ្នាំលើកមុនមកនៅខាងណោះបានមួយឆ្នាំ
ទទួលថៅកែដីហ្នឹងគេដូរមកនៅណោះទូលាយ។

ក៖ហ៊ឺៗ!!

ខ៖អីចឹងវាគិតសរុបទាំងដីចាស់ទាំងដីថ្មីវា៤ឆ្នាំ ឆ្នាំហ្នឹងហើយ។

ក៖ចាំ!!

ខ៖កាលមុនញ៉ុមមកលក់អីចឹងទាល់តែខែលក់ល្មៀសញ៉ុមមកលក់ល្មៀសហើយញ៉ុមត្រលប់
ទៅផ្ទះវិញ ដល់ពេលសោរហ៊ុយក៏វាថ្លៃយើងលក់មិនបានក៏យើងលែងទៅ
កាលកូននៅទូចៗមកលក់អីចឹងល្ងាចត្រលប់ទៅវិញជិះម៉ូតូជាមួយគេអោយសោរហ៊ុយគេ
៣០០០ ៤០០០អីអីចឹងទៅណាស់!!

ក៖ចាំ!!

ខះដល់ឥឡូវវាថ្លៃពេក សុខចិត្តជួលផ្ទះគេទៅ
គិតសព្វគិតគ្រប់ទៅវាមិនលើសគ្នាយើងជួលផ្ទះទៅ។

កះជិតវាស្រួលជាងមីងណោះ?

ខះចាំ!!

កះមិនខាតពេលវេលាធ្វើដំនើរ។

ខះហើយណាវាហាត់រួយចង្កេះរួយអីមីអូនអើយឈឺចង្កេះទៅដល់ផ្ទះវិញ
បើយើងនៅណោះព្រឹកឡើងយើងឡើងលាងឡើងអី
រួចណោះប្រញ៉ែបប្រញាប់ៗហាត់ចង់ដាច់ខ្យល់ហ្នឹង។

កះចាំ!!

ខះបានជួលផ្ទះនៅហ្នឹងអ៊ីចឹងទៅវាស្រួល។

កះចាំ!!អ៊ីចឹងកូនចៅនៅផ្ទះជុំគ្នាហ្នឹងទាំងអស់ម៉ង??

ខះនៅ៣នាក់ម៉ែកូនហ្នឹង។

កះហើយចុះស្វាមី?

ខះប្ដីញ៉ុមមានប្រពន្ធចុងច្រើនណាស់!!បើដឹងថាក្នុងជីវប្រវត្តិងាប់!!

កះហ៊ឺ!!

ខះមីមួយនៅអើរនៅខេត្តស្វាយរៀងស្រីដេរនៅរោងចក្រ
ឆ្នាំ២០០៩ហ៊ឺ!!ត្រលប់ពីហ្នឹងទៅថាពេលថាញ៉ុមឆ្លងទន្លេនៅក្នុងកូនទូចនេះ!!
ថាហ៊ឺមកហ៊ឺអើរចាំមើលឆ្លងទន្លេហើយថាញ៉ុមមិនអោយទៅផ្ទះទេខ្លាចប៉ាញ៉ុមប៉ាអីរករឿងអញ្ចឹ
ង
គេបានលុយគេទៅនៅជាមួយប្រពន្ធចុងគេដ៏ទៅនៅជាមួយប្រពន្ធចុងនោះត្រលប់មកវិញថា
លែងទៅហើយមកអ៊ីចឹងដូចថាបោកប្រាស់យើងអ៊ីចឹងហាំ!!
បានលុយបានកាក់ត្រលប់ទៅវិញទៀត

គិតសព្វទៅមក៣ដងមកមួយសារទៀតថាលែងទៅវិញហើយ
ដល់លែងទៅវិញហើយដាក់៣នាក់ម៉ែកូនហ្នឹងរកលក់ដូរហ្នឹងដាច់នឹកឃើញថាមកនិយាយ
ដដែលៗក៏ញាតិជិតខាងថាហ៊ីង៉ែងជឿវាម្តងទៀតទៅណាស់ក្រែងលោះវាកែ
ញ៉ុមថាវាមិនកែទេ
ឆ្កែនោះ!!!ដល់ហើយក៏ថាមូលគ្នាវិញខំទៅសុំការងារធ្វើនៅផ្លាហ្សាបឹងត្របែករាល់ថ្ងៃហ្នឹង
ធ្វើការមុនដំបូងមួយខែ៩០រៀល
ធ្វើៗទៅសន្សំលុយបានទិញម៉ូតូហ្នឹងខ្ញុំថាទុកលុយទៅយកលុយទៅផ្ញើរប្អូនថ្លៃនៅត្រើយលិច
ហ្នឹង២៥០ ដល់តែបើកលុយទៀតថា ហ៊ីម៉ែងចអើយទិញម៉ូតូ ទិញអាវីវ៉ាពណ៌ក្រហម
ទិញម៉ូតូហ្នឹងហើយលុយហ្នឹងក៏លែងអោយខ្ញុំដែរ អាហ្នឹងជំពាក់គេ
ដល់ឆ្នាំ២០១២ហ្នឹងហិមកនៅដីហ្នឹងហិ!!២០១២អ៊ីចឹតងហើយហ៉ើ២០១៣ទេ!!ការមីកាណោហ្នឹង
មីពៅហ្នឹងការ ការហើយហ៊ីអញទៅដូរម៉ូតូយកអា០១១ណាស់
ជំពាក់លុយគេលុយយើងមិនបាច់យកទេ!!អើរញ៉ុមថាមិនបាច់ៗទៅចុះណាស់
ត្រលប់មកពីការប្អូនថ្លៃហ្នឹងបានដល់ឥឡូវមីអូនយកម៉ូតូអា០១១ហ្នឹងមកដូរយកអា០៥មិនដែ
លចោលផ្ទះទេ លុយកូនក៏មានដែលអោយដែរមីស្រីមីមួយនោះនៅជំបូកខ្ពស់នោះឈ្មោះមីរី
ទៅរកស៊ីលក់ក្រណាត់លក់ខោអាវនៅផ្សារអូរឬស្សីលក់អោយគេប្រាក់ខែមុនដំបូងថា១២០
ហើយដល់ឥឡូវមិនដឹងម៉េចទេ!!ញ៉ុមទាន់នៅផ្លាហ្សាម្តងមីហ្នឹង!!
គ្រាន់តែញ៉ុមថារូបរាងប៉ុណ្ណឹងដឹងថាអាហ្នឹងវាមានប្រពន្ធមានកូនណាស់ !!វា
មានដល់ទៅថៅហើយនៅប្រឹងអីហើយចុះប្តីសាច់ល្អប៉ុណ្ណឹងដែរយកប្តីគេ
ប្តីឯងពីមុនវាអាម៉េចឈឺចាប់អត់មានអារម្មណ៍អាម៉េចណាស់!!!វាថា
ប្តីញ៉ុមវាថាមិនមែនស្រីឬក៏មិនមែនប្រពន្ធទេ!!ប្រពន្ធខ្លើរ ថាខ្លើរអាចមន៍អី!! អាខ្លើរជង្គង់៤
ពួកអាជិះទូកមួយពីនាក់អី!!ញ៉ុមថាអញ្ចឹងហាំ
ញ៉ុមថាចិត្តអញក្តៅមិនទាន់ទេកុំថាមាឌប៉ុណ្ណឹងពីលើផ្លាហ្សាមីយកប្តីញ៉ុមហ្នឹងចាប់ញ៉ុមជាប់ទៅ
អោយមីហ្នឹងចុះតាមជណ្តើរយន្ត បើមិនដឹងថាមីហ្នឹងដល់យូរណាស់
ដល់ក្រោមហ្នឹងមកបានវាប្រលែងញ៉ុមដើរ រកមិនឃើញ ញ៉ុមថាអោយផ្អើលនៅឯផ្លាហ្សាម្តង
ដល់ក្រោយមកទៀតមីហ្នឹងតេមកអាហ្នឹងទៀតកូនញ៉ុមមីនេះវាលើកទូរសព្ទ័ហិ!! ជេរគ្នា
អាឪហ្នឹងកាន់ជើងស្រីអោយគេវ៉ៃកូន ឈឺចាប់ប៉ុណ្ណា!!

កះហ្នឹងហើយ។

ខ៖ហើយគេសុទ្ធតែប្អូនប្រពន្ធគេហ្នឹង ប្រពន្ធគេហ្នឹងប្អូនឯកឧត្តម្ភ
ញ៉ុមមិនចង់និយាយថាសំភាសន៍ទៅវាជះឥទ្ធិពល បើញ៉ុមហែកកេរ្តិ៍អាហ្នឹងត្រូវជាប់គុកទៀត
ចុះបើញ៉ុមថាចុះប្រពន្ធហ្អែងដល់ប្អូនឯកឧត្តម្ភហើយ ហ្អែងមកយកប្តីគេម៉េចហាំ!!!

ក៖ចេះតែបោកហ្នឹងហាំ!!!

ខ៖អញឆ្ងល់!!អោយឯកឧត្តម្ភហ្នឹងមកមើលមុខម្តងមើល!!មែនតែញ៉ុមអត់ចង់និយាយ
អារឿងហ្នឹងឈឺចាប់។

ក៖វាពិបាកណាស់មីងណោះសំរាប់មនុស្សបែបអឺចឹង??

ខ៖យកមីមួយនៅស្រុករមាសហែកបានកូន២ ខ្ញុំវ៉ៃហើយនៅផ្សារដីហុយ ហើយអីហើយទៅ
ពេលវានៅដើរហ្នឹងវាឈ្មោះមីនាងតែអត្តលេខវាញ៉ុមភ្លេចហើយ២៩មិនដឹងទេ!!ដល់ពេលញ៉ុម
តាមទាន់នៅលើកទី៣ញ៉ុមវ៉ៃនៅអើរអាផ្សារដីហុយរោងចក្រហ្នឹងហាំ!!វាពោះធំ
បងថ្លៃញ៉ុមថាហ៊ីពោះវាធំមួយណា?ហ៊ីគេមានពោះធំណា ស្រីដូចតែគ្នា វ៉ៃបែកមាត់
ញ៉ុមទ្រាំមិនបានវ៉ៃបណ្តើរចូលផ្ទះដួលម៉ងទៅ ហ្នឹងឈ្មោះមីហ្នឹងឈ្មោះមីនាង
ដល់នៅស្រុកកំណើតវា គេហៅឈ្មោះវាមីកាផេងនៅខេត្តស្វាយរៀងស្រុករមាសហែក
ហើយប្អូនប្រុសវាឈ្មោះអាយ៉ុង
ដែលប្អូនវាឃាត់ពេកទេពេលហ្នឹងជីដូនមួយខ្ញុំបន្ទាប់ពីខ្ញុំមីស្រស់ហ្នឹងក៏ថាមិនអោយវ៉ៃ
កុំអីញ៉ុមវ៉ៃម្តងទៀតហើយមីហ្នឹងហ្ងំ!! ឥឡូវគេយកបានកូន២ហើយមីហ្នឹង។

ក៖ចំ!!អឺចឹងអ្នកមីងជីវិតរៀងពិបាកហើយអឹចឹង!!

ខ៖ពិបាកហើយឈឺចាប់ទៀត
ឈឺចាប់ហើយក្តៅក្រហាយចង់តែស្រែកយកថាបើសិនជាកាសែតអីញ៉ុមនិយាយទៅពួកវាឈឺ
ចាប់ម៉ង!!សុទ្ធតែពួកអាអំពិលដុះពីអាចមន៍ ខ្ញុំក្តៅក្រហាយណាស់។

ក៖ហ្នឹងហើយ។

ខ៖ញ៉ុមថាពេលគ្រាក្រដឹងនៅឯណាទេ ដល់ពេលមានវាភ្លេចអស់ណាស់!! ញ៉ុមក្តៅក្រហាយ
ពេលអត់យើងមានបន្តិចបន្តួចគាត់មកយើងរកយើង។

ក៖ប្តីមីងហោំ?

ខះហ្នឹងហើយ ពេលមានថាយើងហ្នឹងគំនិតមិនកើត។

កះយ៉ាប់ណាស់មនុស្សប្រុសហ្នឹងហើយ។

ខះមកដៀលយើងទៀត!!ថាសុទ្ធតែយើងស្រីមិនកើតអីមិនអី។

កះអូខេអ៊ីចឹងអរគុណអ្នកមីងសំរាប់និយាយអំពីជីវប្រវត្តិសំរាប់និយាយពីដូនតានិងបងប្អូនហើយអរគុណសំរាប់ការសំភាសន៍ថ្ងៃនេះណាស់អ្នកមីង។